**សន្ទរកថា**

**លោកជំទាវ ម៉ក់ វណ្ណាស៊ីថា អភិបាលរង និងជា**
**ប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ**
**នៅក្នុងកិច្ចប្រជុំសម្របសម្រួលជាន់ខ្ពស់ ស្តីពីការអនុវត្តបទអន្តរាគមន៍**
**បង្ការមេរោគអេដស៍ និង ជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស**
**ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣ នៅសណ្ឋាគារ សាន់វេ**

- សូមគោរព **ឯកឧត្តម អៀង មូលី** ទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- សូមគោរព **ឯកឧត្តមវេជ្ជ តែង គន្ធី** អគ្គលេខាធិការ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។
- ឯកឧត្តម លោកជំទាវ អស់លោក-លោកស្រីជាភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនាពេលនេះ ។

ជាបឋម តាងនាមឲ្យ **ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ** និងក្នុងនាមជាអាជ្ញាធរដែនដី និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ នាងខ្ញុំសូមថ្លែងអំណរគុណចំពោះអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលបានផ្តល់កិត្តិយសឱ្យនាងខ្ញុំបានចូលរួមផ្តល់មតិយោបល់ នៅក្នុងកិច្ចប្រជុំសម្របសម្រួលជាន់ខ្ពស់ស្តីពីការអនុវត្តបទអន្តរាគមន៍ បង្ការមេរោគអេដស៍ និងជំងឺអេដស៍ ក្នុងចំណោមបុរសស្រឡាញ់បុរស។

**ឯកឧត្តម លោកជំទាវ លោក-លោកស្រី ជាទីមេត្រី**

បច្ចុប្បន្ននេះ អត្រាចម្លងមេរោគអេដស៍មានការថយចុះ បើប្រៀបធៀបនឹងឆ្នាំកន្លងមក ប៉ុន្តែការចំណាយទៅលើថ្នាំពន្យាមានការកើនឡើង ហើយអេដស៍ក៏នៅតែជាបញ្ហាមួយដ៏សំខាន់ដែលយើងទាំងអស់គ្នាត្រូវតែបន្តពង្រឹង និងអនុវត្តនូវសកម្មភាពប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដែលកំពុងតែផ្តោតលើក្រុមប្រឈម ក្នុងចំណោមយុវវ័យដែលជាទំពាំងស្នងឬស្សី រួមទាំងឥរិយាបថនៃការប្រព្រឹត្តដែលភាគច្រើនស្ថិតនៅក្នុងតំបន់ទីប្រជុំជនជាពិសេសនៅរាជធានីភ្នំពេញ ។ ក្រុមប្រឈមទាំងនេះ កំពុងតែត្រូវបានចាត់ទុកជាក្រុមដែល

ងាយនឹងធ្វើឲ្យមានការរីករាលដាលមេរោគអេដស៍ និងជំងឺអេដស៍ជាថ្មីនៅកម្ពុជា ជាពិសេសក្រុមបុរសស្រឡាញ់បុរស។ របកគំហើញថ្មីនៃការប្រមូលផ្តុំយុទ្ធសាស្ត្របង្ការមេរោគអេដស៍ដើម្បីសំរេចគោលដៅបីសូន្យ ឆ្នាំ២០១៥-២០២០ របស់អាស៊ី-ប៉ាស៊ីហ្វិក គឺសំដៅផ្តល់នូវឧត្តមប្រយោជន៍ ក្នុងការកាត់បន្ថយអត្រាប្រេវ៉ាឡង់មេរោគអេដស៍ ចំពោះអ្នកប្រើបំពានគ្រឿងញៀន និងដៃគូរួមភេទ ហើយក្នុងនោះយុទ្ធសាស្ត្រសំខាន់ៗដែលកំពុងអនុវត្តមានដូចជា: ការបង្ការ ការព្យាបាលថែទាំគាំពារដោយគ្មានការម៉ាក់ងាយ ការបង្កើតបរិយាកាសគាំទ្រលើកទឹកចិត្ត និងការពង្រឹងសមត្ថភាព ដល់ដៃគូពាក់ព័ន្ធដែលមានសកម្មភាពឆ្លើយតបមេរោគអេដស៍ ជម្ងឺអេដស៍។

ក្នុងនាមអាជ្ញាធរដែនដី ក៏ដូចជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍រាជធានីភ្នំពេញ បានទទួលស្គាល់នូវស្ថានភាពទាំងនេះ ថាជាបញ្ហាមួយបន្ថែមទៀត ហើយតម្រូវឱ្យមានការចូលរួម និងសហការពីអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ អង្គការសង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ទាំងអស់នៅក្នុងរាជធានីភ្នំពេញ។ ទន្ទឹមនេះ ខ្ញុំសូមអំពាវនាវឱ្យឱ្យគណៈកម្មាធិការប្រយុទ្ធនឹងអេដស៍សង្កាត់ និងក្រុមប្រឹក្សាសង្កាត់ បន្តជួយផ្សព្វផ្សាយជំរុញឱ្យមានការប្រើប្រាស់ស្រោមអនាម័យឲ្យបាននៅគ្រប់តំបន់សេវាកំសាន្តសប្បាយ នៅក្នុងមូលដ្ឋានគ្រប់គ្រងរបស់ខ្លួន ព្រមទាំងជួយណែនាំឱ្យក្រុមប្រឈមបុរសស្រឡាញ់បុរស ទៅទទួលសេវាដែលបានកំណត់ដោយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរ ជូនឯកឧត្តម លោកជំទាវ លោក-លោកស្រីទាំងអស់ ឲ្យមានសុខភាពល្អ កម្លាំងមាំមួន ក្នុងការចូលរួមពិភាក្សាឲ្យទទួលបានជោគជ័យទៅតាមកម្មវត្ថុដែលបានគ្រោងទុក ។

**សូមអរគុណ**